## កិច្ចការ២៦:២-២៩

ខ្ញុំបានជម្រាបលើកមុនរួចមកហើយថា ខ្ញុំនឹងអានអត្ថបទទាំងស្រុង ស្តីពីសេចក្តីអធិប្បាយរបស់សាវ័កប៉ុល ចំពោះឥស្សរជនជាន់ខ្ពស់មួយក្រុមក្នុងរាជការរ៉ូម។ ឥឡូវនេះ សូមលោកអ្នកស្តាប់សេចក្តីអធិប្បាយរបស់សាវ័កប៉ុលដូចខាងក្រោមនេះ។ ខ្ញុំសូមអានសេចក្តីបង្រៀនទាំងមូលដោយមិនមានការបង្អាក់អ្វីទេ។ លុះខ្ញុំអានចប់ហើយ ខ្ញុំនឹងពន្យល់គោលសេចក្តីខ្លះៗ។ ខ្ញុំអានពីខ២ គឺគម្ពីរកិច្ចការ២៦:២តទៅ ដើម្បីអោយសាច់រឿងតជាប់គ្នារដឹកក្នុងសេចក្តីអធិប្បាយទាំងមូលរបស់សាវ័កប៉ុល។ ឯសេចក្តីអធិប្បាយនោះ មានរៀបរាប់យ៉ាងពិស្តារដូចតទៅ :

**២ បពិត្រព្រះករុណាអ័គ្រីប៉ាអើយ នៅថ្ងៃនេះទូលបង្គំមានចិត្តអំណរ
ណាស់ ដោយមានច្បាប់នឹងដោះសាខ្លួននៅចំពោះទ្រង់ ពីអស់
ទាំងសេចក្តីដែលសាសន៍យូដាចោទប្រកាន់ទូលបង្គំ ៣ គឺពីព្រោះ
ទ្រង់ជ្រាបគ្រប់ទាំងទំលាប់ នឹងសេចក្តីជជែករបស់ពួកសាសន៍
យូដាជាដើម ដូច្នេះ ទូលបង្គំសូមអង្វរ ឱ្យព្រះករុណាទ្រង់
ព្រះសណ្តាប់ទូលបង្គំ ដោយអំណត់សិន ៤ ដ្បិតពួកសាសន៍យូដា
ទាំងអស់បានស្គាល់ចរិតដែលទូលបង្គំប្រព្រឹត្ត តាំងពីក្មេងមក
ហើយ ថាពីដើមទូលបង្គំនៅកណ្តាលសាសន៍នៃទូលបង្គំនៅក្រុង**

យេរូសាឡិម ៥ហើយបើគេព្រមធ្វើបន្ទាល់ នោះមុខជាគេបាន
ស្គាល់ទូលបង្គំពីដើមមកជាពិតថា ទូលបង្គំបានប្រព្រឹត្តតាមបក្ស
ពួកតឹងរ៉ឹងជាងគេ ក្នុងសាសនានៃទូលបង្គំ គឺជាពួកផារិស៊ី
៦ហើយឥឡូវ ទូលបង្គំជាប់ជំនុំជំរះនេះ នោះគឺដោយព្រោះតែមាន
ចិត្តសង្ឃឹមដល់សេចក្តីសន្យា ដែលព្រះទ្រង់បានតាំងនឹងពួក
ឰយុកោទូលបង្គំ ៧ដែលពូជអំបូរទាំង១២ខំប្រឹងប្រតិបត្តិតាមព្រះ
ទាំងយប់ទាំងថ្ងៃ ដោយសង្ឃឹមនឹងបានសេចក្តីសន្យានោះដែរ
បពិត្រព្រះរាជាអ័គ្រីប៉ាអើយ គឺដោយព្រោះសេចក្តីសង្ឃឹមនោះ
ឯង បានជាពួកសាសន៍យូដា គេចោទប្រកាន់ដល់ទូលបង្គំ ៨ហេតុ
អ្វីបានជាអស់លោកទាំងឡាយរាប់សេចក្តី ដែលព្រះទ្រង់ប្រោស
មនុស្សស្លាប់ឲ្យរស់ឡើងវិញ ថាជាសេចក្តីមិនគួរជឿ ៩ស្ងំឡើទូល
បង្គំក៏បានគិតស្មានថា គួរឲ្យទូលបង្គំធ្វើទាស់ទទឹងជាច្រើន ដល់
ព្រះនាមព្រះយេស៊ូវ ពីស្រុកណាសារ៉ែតដែរ ១០គឺទូលបង្គំបានធ្វើ
ការទាំងនោះនៅក្រុងយេរូសាឡិម បានទាំងចាប់ពួកអ្នកបរិសុទ្ធ
ជាច្រើនយកទៅដាក់គុក ដោយទទួលអំណាចពីពួកសង្គ្រាជមក
ហើយកាលគេសំឡាប់អ្នកទាំងនោះ ទូលបង្គំក៏យល់ព្រមដែរ
១១ទូលបង្គំបានធ្វើទោសគេជាញឹកញយ នៅគ្រប់ទាំងសាលាប្រជុំ
ទាំងបង្ខំឲ្យគេពោលពាក្យប្រមាថដល់ព្រះផង ហើយដោយព្រោះ

ទូលបង្គំមានចិត្តក្តៅក្រហាយជ្រុលពេក ទាស់នឹងគេដូច្នេះ បាន
ជាទូលបង្គំធ្វើទុក្ខបៀតបៀនដល់គេ រហូតដល់ក្រុងនៃសាសន៍
ដទៃផង ១២ នៅគ្រានោះ ទូលបង្គំបានទទួលអំណាច នឹងសេចក្តី
បង្គាប់មកពីពួកសង្គ្រាជ ហើយកំពុងតែដើរដំណើរទៅឯក្រុង
ដាម៉ាស ១៣ នោះបពិត្រព្រះករុណាអើយ នៅពេលថ្ងៃត្រង់ហើយ
ដែលទូលបង្គំកំពុងដើរ នោះស្រាប់តែមានពន្លឺពីលើមេឃ ភ្លឺមក
ជុំវិញទូលបង្គំ នឹងពួកអ្នកដើរជាមួយ ជាពន្លឺភ្លឺជាងថ្ងៃ ១៤ ទូលបង្គំ
ទាំងអស់គ្នាក៏ដួលដល់ដី រួចទូលបង្គំឮសំឡេងមានបន្ទូលមក ជា
ភាសាហេព្រើរថា សុល នៃសុល ហេតុអ្វីបានជាធ្វើទុក្ខដល់ខ្ញុំ
ដែលធាក់ជល់នឹងជន្លួញដូច្នេះ នោះពិបាកដល់អ្នកណាស់ ១៥ ទូល
បង្គំក៏ឆ្លើយថា ឱព្រះអម្ចាស់អើយ តើព្រះអង្គណានុ៎ះ រួច
ទ្រង់មានបន្ទូលថា ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកធ្វើទុក្ខ ១៦ ចូរ
ក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឱ្យអ្នកឃើញ ដើម្បីនឹងតាំង
អ្នក ឱ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ ពីអស់ទាំងការដែលអ្នក
បានឃើញហើយ ព្រមទាំងការ ដែលខ្ញុំនឹងលេចមក ឱ្យអ្នកឃើញ
ទៅមុខទៀត ១៧ ខ្ញុំបានញែកអ្នកចេញពីបណ្តាជន នឹងពីពួកសាសន៍
ដទៃ ដើម្បីនឹងចាត់អ្នកឱ្យទៅឯគេវិញ ១៨ ប្រយោជន៍នឹងបំភ្លឺភ្នែក
គេ ឱ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាច

អារក្សសាតាំង មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប ហើយបាន
ទទួលមរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយ
សារសេចក្តីជំនឿជឿដល់ខ្ញុំ ១៩ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ
ទូលបង្គំមិនបានចចេសនឹងការជាក់ស្តែងពីស្ថានសួគ៌នោះទេ ២០គឺ
ទូលបង្គំបានប្រាប់ឱ្យមនុស្សទាំងអស់ប្រែចិត្ត ហើយងាកបែរមកឯ
ព្រះវិញ ទាំងប្រព្រឹត្តបែបសំណាំនឹងការប្រែចិត្តផង គឺប្រាប់ដល់ពួក
អ្នកដែលនៅក្រុងដាម៉ាសជាមុនដំបូង រួចនៅក្រុងយេរូសាឡិម
នឹងគ្រប់ក្នុងខេត្តយូដា ហើយដល់អស់ទាំងសាសន៍ដទៃផង
២១ដោយហេតុនោះបានជាពួកសាសន៍យូដា ចាប់ទូលបង្គំនៅក្នុង
ព្រះវិហារ ហើយព្យាយាមនឹងសំឡាប់ទូលបង្គំចោល ២២តែព្រះ
ទ្រង់បានជួយទូលបង្គំ ដរាបមកដល់ថ្ងៃនេះ បានជាទូលបង្គំឈរ
ធ្វើបន្ទាល់ដល់អ្នកតូចធំ ដោយគ្មាននិយាយអ្វី ឱ្យលើសពីសេចក្តី
ដែលពួកហោរា នឹងលោកម៉ូសេបានទាយថាត្រូវមកនោះឡើយ
២៣គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខ ហើយថា ដោយសារទ្រង់មានព្រះ
ជន្មរស់ពីស្លាប់ឡើងវិញមុនគេទាំងអស់ នោះទ្រង់បានប្រកាស
ប្រាប់ពីពន្លឺ ដល់សាសន៍នេះ ហើយដល់សាសន៍ដទៃផង (កិច្ចការ
២៦:២-២៣)។

បន្ទាប់ពីសាវ័កប៉ុលពន្យល់អំពីចរិតរបស់លោកតាំងពីក្មេងមក លោកទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ាថា លោកធ្លាប់ធ្វើជាសមាជិកគណៈកម្មាធិការជាន់ខ្ពស់ខាងសាសនាក្នុងគណៈផារិស៊ី។ រួចហើយ លោកទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ាអំពីបទពិសោធន៍របស់លោក ដែលលោកជួបជាមួយនឹងព្រះអម្ចាស់យេស៊ូវនៅតាមផ្លូវ ដែលលោកកំពុងធ្វើដំណើរទៅទីក្រុងដាម៉ាស។

សាវ័កប៉ុលបញ្ជាក់ដល់អ្នកស្តាប់ទាំងអម្បាលមាណថា "សូម្បីទូលបង្គំក៏បានគិតស្មានថា គួរឱ្យទូលបង្គំធ្វើទាស់ទទឹងជាច្រើន ដល់ព្រះនាមព្រះយេស៊ូវ ពីស្រុកណាសារ៉ែតដែរ" (៩)។ នៅក្នុងចំណោមមនុស្សលោកដែលចងអាឃាតជាមួយនឹងព្រះអម្ចាស់យេស៊ូវ មិនមាននរណាដែលចងអាឃាតអោយខ្លាំងលើសជាងលោកសុល ជាអ្នកស្រុកតើសុសឡើយ។ លោកជាមនុស្សម្នាក់ដែលស្អប់ព្រះយេស៊ូវដោយមានចិត្តជូរចត់ជាទីបំផុត។ លោកស្អប់នាមព្រះយេស៊ូវគ្រីស្ទ ព្រមទាំងស្អប់ដំណឹងល្អរបស់ព្រះអង្គផង។ លោកទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ាថា លោកបានធ្វើទុក្ខបុកម្នេញពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ដែលជាសមាជិករបស់ក្រុមជំនុំនៅទីក្រុងយេរូសាឡិម។ មិនតែប៉ុណ្ណោះ លោកចាប់ពួកអ្នកជឿទាំងអម្បាលមាណយកទៅដាក់គុកដោយឥតត្រាប្រណីអ្វីឡើយ។ ដោយសារមូលហេតុនេះហើយ បានជាលោកចាំបាច់ត្រូវរងទុក្ខចំនួនពីរឆ្នាំនៅក្នុងពន្ធនាគារដោយសារដៃរបស់មេដឹកនាំសាសនាយ៉ាងដូច្នេះដែរ។ ឥឡូវនេះ លោកប៉ុលបានក្លាយត្រឡប់ទៅជាអ្នកទោសមួយរូប ដូចអ្នកដែលលោកធ្លាប់ធ្វើបាបគេពីដើម។ ដោយហេតុនោះ បានជាលោកជ្រាបច្បាស់អំពីទុក្ខលំបាកដែលគ្រីស្ទបរិស័ទ

កាលលោកចាប់គេចងថា តើគេមានអារម្មណ៍យ៉ាងណា។

នៅក្នុង៦១៣ សាវ័កប៉ុលទូលថ្វាយព្រះរាជាអ័គ្រីប៉ា អំពីបទពិសោធន៍ដែលលោកជួបជាមួយនឹងព្រះអម្ចាស់យេស៊ូវនៅតាមផ្លូវ ដែលលោកធ្វើដំណើរទៅទីក្រុងដាម៉ាស។ នៅពេលនោះ ព្រះយេស៊ូវជួបជាមួយនឹងសាវ័កប៉ុល ដោយបញ្ចាំងពន្លឺទ្រង់ពីលើមេឃអោយភ្លឺជុំវិញលោក។ រួចហើយព្រះអម្ចាស់យេស៊ូវមានបន្ទូលផ្ទាល់មកកាន់លោកនៅក្នុងពេលនោះ។ បន្ទាប់ពីសាវ័កប៉ុលស្តាប់យល់ព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវហើយ លោកយល់ថា លោកបានធ្វើទាស់ទទឹងជាមួយនឹងបំណងព្រះហឫទ័យរបស់ព្រះអង្គដោយបានសម្លាប់សង្ឃបរិសុទ្ធរបស់ទ្រង់។ ហេតុដូច្នេះហើយ បានជាប៉ុន្មានឆ្នាំក្រោយមកទៀត លោកសរសេរសំបុត្របញ្ជាក់ទៅពួកជំនុំនៅទីក្រុងភីលីព អំពីបទពិសោធន៍នេះ។ នៅក្នុងសំបុត្រនោះលោកសរសេរថា "ប៉ុន្តែ សេចក្តីអ្វីដែលមានប្រយោជន៍ដល់ខ្ញុំពីមុន នោះខ្ញុំបានរាប់ជាខាតវិញ ដោយព្រោះព្រះគ្រីស្ទ ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេចក្តីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ ដែលដោយយល់ដល់ទ្រង់ ខ្ញុំបានខាតគ្រប់ទាំងអស់ ហើយបានរាប់ទាំងអស់ទុកដូចជាសំរាម ប្រយោជន៍ឱ្យបានព្រះគ្រីស្ទវិញ" (ភីលីព៣:៧-៨)។ សាវ័កប៉ុល ពិតជាមានការបដិវត្តន៍នៅក្នុងគំនិតនិងជីវិតរបស់លោកជាពិតប្រាកដ។ កន្លងមកលោកជឿទុកចិត្តដល់សាសនារបស់លោក ឥតងាកឆ្វេងនិងងាកស្តាំឡើយ។ ប៉ុន្តែ ចាប់ពីពេលនោះមក លោកបានជឿដល់ព្រះអម្ចាស់យេស៊ូវ ដែលញុំាងអោយសាសនារបស់លោក លែងរាប់ថាជាទីសង្ឃឹមដល់លោកទៀត។ អ្វីៗដែលលោក

យល់ថាជាកម្រៃ និងរាប់ថាជាការចេះដឹងទាំងអម្បាលមាណពីការសិក្សាអប់រំ ពីការកាន់សាសនា លោករាប់ការទាំងនោះថាជាការខាតបង់ឥតប្រយោជន៍វិញ។ ព្រះអម្ចាស់យេស៊ូវដែលលោកស្អប់ជាងនរណាទាំងអស់ពីដើមនោះ ឥឡូវ បានក្លាយត្រឡប់ទៅជាព្រះមួយអង្គដែលមានសារៈសំខាន់ស្លាប់រស់សម្រាប់ជីវិតរបស់លោក។

បន្ទាប់មកទៀត សាវ័កប៉ុលបរិយាយអំពីភាពពិតនៃនិម្មិតរបស់លោក ដើម្បីជម្រាបដល់លោកអភិបាលខេត្តភេស្ទុស និងថ្វាយដល់ព្រះរាជាអ័គ្រីប៉ា។ លោកមានប្រសាសន៍ទូលនិងថ្វាយថា ព្រះអម្ចាស់យេស៊ូវបានបង្គាប់ដល់លោក អោយអធិប្បាយដល់សាសន៍ដទៃ។ លោកជម្រាបទៀតថា ព្រះអង្គសន្យានឹងការពារគ្រប់ទាំងគ្រោះថ្នាក់ដែលលោកត្រូវឆ្លងកាត់ ទំរាំដល់ពេលកំណត់។ ប្រសាសន៍របស់សាវ័កប៉ុលពីដំណើរនេះ ហាក់ដូចជាធ្វើអោយមេដឹកនាំនយោបាយពីររូប ដែលមានអំណាចយ៉ាងខ្លាំងក្លាមិនអាចប៉ះពាល់ដល់រូបលោកផ្ទាល់បាន ពីព្រោះឥឡូវនេះ ក្រោមច្បាប់តុលាការរាជការរ៉ូម លោកត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់មហារាជ្យសេសារអូគូស្ទផ្ទាល់។ សិទ្ធិអំណាចនេះកើតឡើង ដោយសារលោកបានសូមរើក្តីទៅថ្វាយព្រះរាជាកាត់ទោសលោកវិញ។ ដំណើរនេះ បើមើលតាមផ្លូវច្បាប់តុលាការរាជការរ៉ូម ដំណើររឿងនេះជាការបញ្ជូនសាវ័កប៉ុល ទៅអោយទទួលការកាត់ទោសពីសាលាជំនុំជំរះក្តីជាន់ខ្ពស់នៅឯទីក្រុងរ៉ូម។ ប៉ុន្តែ ចំពោះភ្នែករបស់សាវ័កប៉ុល និងព្រះនេត្ររបស់ព្រះវិញ ព្រះអង្គបញ្ជូនសាវ័កប៉ុលអោយទៅអធិប្បាយដល់ដំណាក់របស់ព្រះរាជា គឺមហារាជ្យសេសារអូគូស្ទ។

លុះដល់ខ១៩ សាវ័កប៉ុលទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា អំពីការឆ្លើយតបរបស់លោក ចំពោះនិមិត្តដែលព្រះអម្ចាស់យេស៊ូវបានបើកសម្តែងមកនោះ។ លោកទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ាថា "ដូច្នេះ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការជាក់ស្តែងពីស្ថានសួគ៌នោះទេ"។ បើយើងនិយាយជាភាសាសាមញ្ញធម្មតាបាន យើងអាចពោលពាក្យរបស់សាវ័កប៉ុលម្តងទៀតថា "បើព្រះរាជា ជាទូលបង្គំវិញ តើព្រះអង្គឆ្លើយតបជាមួយនឹងព្រះអម្ចាស់យេស៊ូវបែបណាដែរ? ព្រះរាជាពិតជាឆ្លើយតបជាមួយនឹងព្រះអម្ចាស់យេស៊ូវដោយព្រមជឿថា ព្រះអង្គបានត្រាស់ហៅព្រះរាជាមែនទេ?"

ចាប់តាំងពីសាវ័កប៉ុលសម្តែងការអធិប្បាយនេះមក លោកមានប្រសាសន៍ថា "ផ្លូវនោះ" គឺជាតំណាក់កាលបន្តបន្ទាប់ ដើម្បីធ្វើអោយបទទំនាយនានានៅក្នុងព្រះគម្ពីរសញ្ញាចាស់បានសម្រេចចេញជារូបរាងឡើង។ លោកទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា អំពីដំណើរនេះថា "តែព្រះទ្រង់បានជួយទូលបង្គំ ដរាបមកដល់ថ្ងៃនេះ បានជាទូលបង្គំឈរធ្វើបន្ទាល់ដល់អ្នកតូចធំ ដោយគ្មាននិយាយអ្វី ឲ្យលើសពីសេចក្តី ដែលពួកហោរា នឹងលោកម៉ូសេបានទាយថាត្រូវមកនោះឡើយ" (ខ២២)។ សេចក្តីដែលសាវ័កប៉ុលឆ្លើយតបចំពោះព្រះជាម្ចាស់ ក្នុងនិម្មិតរបស់លោក មិនមែនជាសេចក្តីអ្វីដែលទាស់ទទឹងជាមួយនឹងព្រះគម្ពីរសញ្ញាចាស់ទេ។

នៅក្នុងពេលនេះ សាវ័កប៉ុលបានប្រកាសទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា អំពីដំណឹងល្អហើយ។ ចំណែកមនុស្សដទៃៗទៀត ដែលជាឥស្សរជនជាន់ខ្ពស់របស់រាជការ

រ៉ូម ក៏បានឮខ្លឹមសារនៃដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវដែរ។ ឯដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវដែលសាវ័កប៉ុលប្រកាសនៅក្នុងពេលនេះ "គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខ ហើយថាដោយសារទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញមុនគេទាំងអស់ នោះទ្រង់បានប្រកាសប្រាប់ពីពន្លឺ ដល់សាសន៍នេះ ហើយដល់សាសន៍ដទៃផង" (២២៣)។ ខ្ញុំយល់ថា សាវ័កប៉ុលសង្កត់ន័យយ៉ាងខ្លាំង ចំពោះពាក្យសាសន៍ដទៃ ពីព្រោះព្រះរាជាអ័គ្រីប៉ា ក៏ជាសាសន៍ដទៃ។ ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលសាវ័កប៉ុលប្រកាសនៅក្នុងពេលនេះគឺ ព្រះគ្រីស្ទសុគតជំនួសអំពើបាបរបស់យើង។ ទ្រង់ត្រូវគេយកទៅបញ្ចុះនៅក្នុងផ្នូរចំនួនបីថ្ងៃ រួចហើយទ្រង់រស់ពីសុគតឡើងវិញ។ សាវ័កប៉ុលតែងតែសង្កត់ន័យយ៉ាងខ្លាំងទៅលើកត្តាដែលថា ព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ។ លោកអ្នកបងប្អូនដែលជាគ្រីស្ទបរិស័ទ បើលោកអ្នកបានប្រកាសថា ព្រះអម្ចាស់យេស៊ូវទ្រង់សុគត ប៉ុន្តែមិនបានប្រកាសថា ព្រះយេស៊ូវទ្រង់រស់ពីសុគតឡើងវិញនោះទេ លោកអ្នកពិតជាមិនបានប្រកាសដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវប្រាប់ដល់មនុស្សលោកឡើយ។ សាវ័កប៉ុលប្រកាសប្រាប់ឥស្សរជនជាន់ខ្ពស់របស់រាជការរ៉ូម និងព្រះរាជាអ័គ្រីប៉ា អំពីហេតុការណ៍ដែលព្រះជាម្ចាស់បានយាងចុះមកបំពេញប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ពីព្រោះព្រះអង្គបានបង្កើតមនុស្សជាតិមក។ ព្រះអង្គស្រឡាញ់ដល់មនុស្សជាតិណាស់ បានជាព្រះអង្គបញ្ជូនព្រះរាជបុត្រារបស់ទ្រង់តែមួយអង្គគត់ អោយមកសុគតជំនួសអំពើបាបមនុស្សជាតិ។

កំពុងតែសាវ័កប៉ុលអធិប្បាយ ហើយមានមនុស្សស្តាប់យ៉ាងយកចិត្តទុកដាក់

លោកអភិបាលខេត្តភេស្ទុស ក៏បានបង្អាក់ដំណើរលោក។ នៅពេលដែលអភិបាលខេត្តរូប នេះឮរឿងរបស់ព្រះអម្ចាស់យេស៊ូវ លោកអង្គុយមិនកើតទៀតទេ ពីព្រោះកៅអីរបស់ លោកក្តៅយ៉ាងខ្លាំង។

> **[២៤]កំពុងដែលគាត់និយាយសេចក្តីទាំងនោះ ដើម្បីដោះសាខ្លួន នោះលោកភេស្ទុសឡើងសំឡេងកាត់ថា ប៉ុលអើយ ឯងឆ្កួតទេ ឯងរៀនសូត្រជាច្រើនដល់ម៉្លេះ បានជាឆ្កួតហើយ [២៥]តែគាត់ ប្រកែកថា ព្រះតេជព្រះគុណភេស្ទុសអើយ ខ្ញុំប្របាទមិនមែនឆ្កួត ទេ ខ្ញុំប្របាទនិយាយចំពោះពាក្យពិត ហើយជានាទេតើ (កិច្ចការ ២៦:២៤-២៥)។**

លោកអភិបាលខេត្តភេស្ទុស មិនគួរនិយាយកាត់សាវ័កប៉ុលត្រង់ចំណុចនេះ ទេ។ ប៉ុន្តែ ឯសាវ័កប៉ុលវិញ បានឆ្លើយតបជាមួយនឹងលោកអភិបាលខេត្តភេស្ទុស ដោយកិរិយាស្លូតបូតជាទីបំផុត។ ការឆ្លើយតបដោយចិត្តសុភាពរាបសារ សម្តែងថា សាវ័កប៉ុលមិនមែនជាមនុស្សឆ្កួត ឬជាមនុស្សលង់ក្នុងសាសនា ដូចលោកអភិបាលខេត្ត ភេស្ទុសបានចោទលោកនោះទេ។

សម័យសព្វថ្ងៃនេះ មានគ្រូអធិប្បាយព្រះបន្ទូលជាច្រើន មិនសូវហ៊ាននិយាយ ព្រះបន្ទូលរបស់ព្រះអង្គ ដែលជាសេចក្តីពិតអោយមនុស្សស្តាប់តាមត្រង់ៗនោះទេ។ ខ្លះ

គេថា និយាយត្រង់ពេកធ្វើអោយមនុស្សលោកជៀលថា យើងជាមនុស្សឆ្កួត។ លោកអ្នកបងប្អូនអើយ ក្នុងនាមយើងជាអ្នកប្រកាសសេចក្តីពិតពីព្រះបន្ទូលរបស់ព្រះ នៅក្នុងដំណឹងល្អនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងត្រូវសូមកម្លាំងពីព្រះអង្គអោយគេចោទថា យើងឆ្កួតចុះ ប៉ុន្តែ សូមលោកអ្នកកុំធ្វើជាមនុស្សឆ្កួតដូចគេថាមែន។ យើងត្រូវប្រកាសដំណឹងល្អដោយចិត្តសុភាពរាបសារ ដូចជាសាវ័កប៉ុលប្រកាសដំណឹងល្អដល់ឥស្សរជនជាន់ខ្ពស់នៃរាជការរ៉ូម។

បន្ទាប់ពីលោកឆ្លើយតបជាមួយនឹងលោកអភិបាលខេត្តភេស្ទុស សាវ័កប៉ុលបានដណ្តឹងសួរដល់ព្រះរាជាអ័គ្រីប៉ា ដោយសំណួរមួយដែលទាក់ទងជាមួយនឹងជីវិតអស់កល្បជានិច្ច សម្រាប់ព្រះរាជាអង្គនេះផ្ទាល់។

> **២៦ ដ្បិតព្រះករុណាទ្រង់បានជ្រាបការទាំងនេះហើយ ខ្ញុំប្របាទក៏ទូលដល់ទ្រង់ដោយក្លាហានដែរ ព្រោះខ្ញុំប្របាទជឿប្រាកដថា ក្នុងការទាំងនេះគ្មានអ្វីលាក់កំបាំងនឹងទ្រង់ទេ ដ្បិតមិនមែនធ្វើនៅទីកៀនកោះឯណាឡើយ ២៧ បពិត្រព្រះរាជាអ័គ្រីប៉ាអើយ តើទ្រង់ជឿសេចក្តីទំនាយរបស់ពួកហោរាឬទេ ទូលបង្គំដឹងថាទ្រង់ជឿហើយ (កិច្ចការ២៦:២៦-២៧)។**

ធម្មតាមនុស្សយើងមិនមែនជឿអ្វីមួយ ដោយគ្មានហេតុផលច្បាស់លាស់នោះ

ទេ។ រឿងនេះ ដូចគ្នាជាមួយនឹងជំនឿលើដំណឹងល្អដែរ។ បើយើងមិនយល់ហេតុការណ៍នៃដំណឹងល្អអោយបានច្បាស់លាស់ទេ យើងមិនអាចជឿលើដំណឹងល្អនោះបានឡើយ។ ឯដំណឹងល្អដែលយើងត្រូវជឿច្បាស់លាស់នោះ គឺថា តើយើងជឿថាព្រះអម្ចាស់យេស៊ូវសុគតជំនួសអំពើបាបយើងដែរឬទេ? តើយើងជឿថា ព្រះយេស៊ូវដែលគេបញ្ចុះទ្រង់នៅក្នុងផ្នូរ គឺអំពើបាបរបស់យើងត្រូវកប់ជាមួយនឹងព្រះអង្គហើយដែរទេ? តើយើងជឿថា ព្រះយេស៊ូវរស់ពីសុគតឡើងវិញ ដើម្បីធ្វើជាអង្គសង្គ្រោះរបស់យើងដែរឬ? ជំនឿលើកត្តាទាំងបីយ៉ាងនេះ ហៅថាជំនឿលើដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ជំនឿរបស់លោកអ្នក ញ៉ាំងអោយទំនាក់ទំនងរបស់លោកអ្នកជាមួយនឹងព្រះអម្ចាស់យេស៊ូវ មានភាពជិតស្និទ្ធ ឬមួយក៏មានភាពដាច់ឆ្ងាយពីគ្នា។ ទំនាក់ទំនងលោកអ្នកជាមួយព្រះអម្ចាស់យេស៊ូវក្នុងពេលដែលលោកអ្នករស់នៅ គឺជាជំនឿដែលសម្រេចវាសនារបស់លោកអ្នកនៅក្នុងគ្រាអនន្តកាល។ បើលោកអ្នកជឿលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ វាសនាអនន្តកាលរបស់លោកអ្នក ត្រូវរស់នៅស្ថានសួគ៌ជាមួយនឹងព្រះអម្ចាស់យេស៊ូវរហូតដល់អស់កល្បជានិច្ចតរៀងទៅ។ ផ្ទុយទៅវិញ បើលោកអ្នកបដិសេធមិនព្រមជឿលើដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវទេ វាសនារបស់លោកអ្នកនៅក្នុងគ្រាអនន្តកាល គឺចំណាយពេលអស់កល្បជានិច្ចនៅក្នុងស្ថាននរកដាច់ពីព្រះអម្ចាស់យេស៊ូវគ្រីស្ទតរៀងទៅ។ ខ្ញុំផ្ទាល់ សូមអំពាវនាវដល់លោកអ្នកបងប្អូនដែលឮព្រះបន្ទូលរបស់ព្រះអម្ចាស់ហើយ សូមកុំបណ្តោយខ្លួនបដិសេធមិនព្រមជឿដល់ដំណឹងល្អរបស់ព្រះយេស៊ូវសោះឡើយ។

សាវ័កប៉ុល ទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ា សុំអោយទ្រង់ទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះរបស់ទ្រង់ទៅ។ តែនៅពេលនោះព្រះរាជាអ័គ្រីប៉ា មានបន្ទូលឆ្លើយតបមកលោកប៉ុលថា :

**២៨ ស្ដេចអ័គ្រីប៉ាក៏មានបន្ទូលទៅប៉ុលថា បន្តិចទៀត ឯងនឹងនាំឱ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទានដែរ ២៩ រួចប៉ុលទូលថា ទូលបង្គំសូមដល់ព្រះ មិនមែនឱ្យត្រឹមតែព្រះករុណាប៉ុណ្ណោះ គឺឱ្យអស់អ្នកដែលស្ដាប់ទូលបង្គំនៅថ្ងៃនេះថែមទៀតផង ទោះបើនៅបន្តិចទៀត ឬយូរទៅទៀតក្ដី ឱ្យតែគ្រប់គ្នាបានដូចទូលបង្គំ លើកតែចំណងនេះចេញ (កិច្ចការ២៦:២៨-២៩)។**

ព្រះរាជាអ័គ្រីប៉ា ជាមនុស្សឆ្លាតវាងវៃពិបាករកស្ដេចណាមកប្រៀបប្រដូចជាមួយនឹងទ្រង់ណាស់។ លោកឆ្លើយទៅសាវ័កប៉ុលថា "បន្តិចទៀត ឯងនឹងនាំឱ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទានដែរ"។ ព្រះរាជាអ័គ្រីប៉ាគ្រាន់តែបិះក្លាយទៅជាអ្នកគ្រីស្ទាន។ ស្ដេចអង្គនេះ មិនបានក្លាយទៅជាកូនរបស់ព្រះទេ។ កិរិយារបស់លោករាប់ថាជាកិរិយាអកុសលជាទីបំផុត ពីព្រោះស្ដេចអង្គនេះ មិនបានទៅនៅជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទអស់កល្បជានិច្ចតរៀងទៅ។ ការបិះនឹងបានទៅនៅស្ថានសួគ៌ គឺធ្លាក់នរកហើយ។ ការប្រឡងបិះជាប់ ហើយនិងការប្រឡងបិះធ្លាក់ ខុសគ្នាឆ្ងាយណាស់។ អ្នកប្រឡងបិះ

ធ្លាក់ ទទួលបានសញ្ញាប័ត្រ តែបើប្រឡងបិះជាប់វិញ ភាសាបារាំងគេនិយាយថា សេរតាផ្លាកហើយ។ ចំពោះយើងទាំងអស់គ្នាដែលជាមនុស្ស យើងមានការសម្រេចចិត្តតែពីរយ៉ាងគត់ ឬមួយក៏យើងទទួលព្រះអម្ចាស់យេស៊ូវ ឬមិនទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ។ សេចក្តីសង្គ្រោះដែលទទួលបានតាមរយៈព្រះអម្ចាស់យេស៊ូវ មិនដែលមានអ្នកប្រាជ្ញាណាយល់អោយបានច្បាស់លាស់ទេ។ ប៉ុន្តែសេចក្តីសង្គ្រោះនោះមានលក្ខណៈងាយល្មមសម្រាប់អោយមនុស្ស ដែលល្ងង់ប្រហែលយើងទាំងអស់គ្នាអាចយល់បាន។ លោកអ្នកអាចមានព្រះអម្ចាស់យេស៊ូវគ្រីស្ទ ឬគ្មានព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លោកអ្នកអាចទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ឬមិនទុកចិត្តលើព្រះអង្គ។ លោកអ្នកអាចសម្រេចចិត្តទទួលអង្គព្រះយេស៊ូវជាអង្គសង្គ្រោះ ឬទ្រង់មិនមែនជាអង្គសង្គ្រោះរបស់លោកអ្នកទេ។ នៅក្នុងចំណោមដំណើរពីរនេះ លោកអ្នកជ្រើសរើសបានតែមួយមុខប៉ុណ្ណោះ។ លោកអ្នកមិនអាចជ្រើសរើសផ្លូវកណ្តាលបានទេ ពីព្រោះបើលោកអ្នកជ្រើសរើសផ្លូវកណ្តាល លោកអ្នកបិះបានរួចពីបាបជាពិតប្រាកដ។

សាវ័កប៉ុលឆ្លើយតបជាមួយនឹងព្រះរាជាអ័គ្រីប៉ាថា "...ទូលបង្គំសូមដល់ព្រះ មិនមែនឱ្យត្រឹមតែព្រះកុរណាប៉ុណ្ណោះ គឺឱ្យអស់អ្នកដែលស្តាប់ទូលបង្គំនៅថ្ងៃនេះថែមទៀតផង ទោះបើនៅបន្តិចទៀត ឬយូរទៅទៀតក្តី ឱ្យតែគ្រប់គ្នាបានដូចទូលបង្គំ លើកតែចំណងនេះចេញ"។ ទឹកចិត្តរបស់សាវ័កប៉ុល គឺចង់អោយមនុស្សដែលស្តាប់លោកទាំងអម្បាលមាណមានទំនាក់ទំនងជាប់ជាមួយនឹងព្រះអម្ចាស់យេស៊ូវ លើកលែងតែច្រវាក់ដែលដាក់ដៃលោកតែប៉ុណ្ណោះ។ សាវ័កប៉ុលមិនចង់អោយច្រវាក់ជាប់ដៃលោក

តទៅទៀតទេ។ សាវ័កប៉ុល គឺជាអ្នកកាន់សាសនាមួយរូប ក្នុងគណៈផារិស៊ី។ លោកមានចិត្តឧស្សាហ៍ណាស់។ ប៉ុន្មានឆ្នាំមុននេះ លោកចងអ្នកគ្រីស្ទាន ព្រមទាំងយកគេទៅប្រហារជីវិតផង។ ប៉ុន្តែ ក្នុងពេលនេះ លោកមិនមែនជាសត្រូវរបស់គ្រីស្ទបរិស័ទទៀតទេ គឺលោកជាកូនរបស់ព្រះដ៏ខ្ពស់បំផុត ព្រមទាំងមានទំនាក់ទំនងផ្ទាល់យ៉ាងល្អជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

យើងឃើញមានការផ្លាស់ប្រែយ៉ាងខ្លាំង ដល់ជីវិតរបស់លោកសុលនៅស្រុកតើសុស។ ហេតុអ្វីបានជាលោកមានការផ្លាស់ប្រែ ដូចថ្ងៃហើយនិងយប់យ៉ាងដូច្នេះ? ពីព្រោះព្រះយេស៊ូវជាអង្គរស់នៅសព្វថ្ងៃ។ ព្រះអង្គមិនសុគតជារៀងរហូតទេ។ ដូច្នេះហើយ បានជាសាវ័កប៉ុលទូលថ្វាយដល់ព្រះរាជាអ័គ្រីប៉ាថា "ហេតុអ្វីបានជាអស់លោកទាំងឡាយរាប់សេចក្តី ដែលព្រះទ្រង់ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ថាជាសេចក្តីមិនគួរជឿ?" (កិច្ចការ២៦:៨)។ ការដែលព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ ជាការដែលយើងគួរជឿខ្លាំងណាស់។ ក្នុងរយៈពេល២០០០ឆ្នាំកន្លងទៅ មានការស្រាវជ្រាវរបស់មនុស្សខំប្រឹងរកអោយឃើញថា រឿងរបស់ព្រះអម្ចាស់យេស៊ូវរស់ឡើងវិញ ពិតជាកើតឡើងយ៉ាងដូច្នោះមែន ឬមួយយ៉ាងណា? កន្លងមកគេរកឃើញភ័ស្តុតាងច្រើនណាស់ ដែលបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទពិតជារស់ឡើងវិញមែន។

ដោយសារព្រះអម្ចាស់យេស៊ូវជាព្រះដ៏រស់ពីសុគតឡើងវិញ ទ្រង់នឹងយាងត្រឡប់មកផែនដីនេះម្តងទៀត ដើម្បីជំនុំជំរះមនុស្សលោក។ ទ្រង់យាងមកវិញដោយគង់លើបល្ល័ង្គស។ ឯអ្នកដែលត្រូវមកទទួលការកាត់ទោសពីព្រះអម្ចាស់យេស៊ូវ គឺជា

អ្នកទោស។ ឯអ្នកទោសនោះទៀតសោត គឺខ្ញុំហើយនិងលោកអ្នកបងប្អូន។ លោកអ្នកអាចជ្រើសរើសទទួលជឿព្រះយេស៊ូវក្នុងជីវិតនេះ ឬមួយចាំបាច់ត្រូវឈរនៅចំពោះព្រះអម្ចាស់យេស៊ូវដោយតក់ស្លត់ នៅថ្ងៃជំនុំជំរះនៅពេលព្រះអង្គគង់នៅលើបល្ល័ង្កស។ ក៏លោកអ្នកបងប្អូនអាចឈរនៅចំពោះព្រះអង្គទុកចិត្តថា ព្រះអម្ចាស់យេស៊ូវប្រកាសថាយើងជាអ្នករួចខ្លួនដោយបានជឿដល់ព្រះអម្ចាស់យេស៊ូវកាលយើងនៅរស់។ សេចក្តីរស់ឡើងវិញ របស់ព្រះអម្ចាស់យេស៊ូវមានសារៈសំខាន់ ចំពោះមនុស្សដែលមិនទាន់ជឿដល់ព្រះអម្ចាស់យេស៊ូវ ក៏ដូចជាមនុស្សដែលជឿដល់ព្រះអម្ចាស់យេស៊ូវរួចហើយដែរ។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"